/

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខៈ ...២.១១១.........កប-ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតសញ្ញារបស់បេឡាជាតិរបបសន្តិសុខសង្គម

### ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យ លេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតសញ្ញារបស់បេឡាជាតិរបបសន្តិសុខសង្គម សម្រាប់ប្រើប្រាស់ជាផ្លូវការ ។

**ប្រការ ២.-**

សញ្ញារបស់បេឡាជាតិរបបសន្តិសុខសង្គម ដូចមាននៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ត្រូវបានកំណត់ដូចតទៅ :

- មានរូបរាងទាំងមូល រាងមូល ព័ទ្ធដោយកួរស្រូវរាងស្នែងក្របីពណ៌ទឹកមាស រូបរាងខាងក្នុងមានរូបមនុស្ស ប្រុស-ស្រី នៅខាងក្នុងកងចក្រ និងគម្របពណ៌ទឹកសមុទ្ររាងជាពាក់កណ្ដាលរង្វង់ ។ នៅលើផ្ទៃគម្របកងចក្រមានសរសេរអក្សរ " ប.ស.ស " និង " NSSF " ។ ព័ទ្ធជុំវិញកងចក្រមានជុំតួអក្សររាងជារង្វង់ដាក់ថា "បេឡាជាតិរបបសន្តិសុខសង្គម" និង " National Social Security Fund"
- កួរស្រូវពណ៌ទឹកមាសមាន ៩ ថ្នាក់ តំណាងនូវតាវកាលិកទាំងប្រាំបួន ដែលត្រូវអនុវត្តជាជំហាន១ស្របតាមស្ថានភាពសេដ្ឋកិច្ច សង្គម
- អក្សរ បេឡាជាតិរបបសន្តិសុខសង្គម និង National Social Security Fund ពណ៌ទឹកសមុទ្រ រាងជារង្វង់ តំណាងឈ្មោះគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានបេសកកម្មក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ
- រូបពាក់កណ្ដាលរង្វង់គ្របពីលើកងចក្រ ពណ៌ទឹកសមុទ្រ ដែលមានអក្សរ ប.ស.ស និង NSSF ពណ៌ស តំណាងនូវការការពារហានិភ័យសង្គមចំពោះកម្មករនិយោជិតដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ
- រូបកងចក្ររាងពាក់កណ្ដាលរង្វង់ពណ៌ទឹកសមុទ្រ តំណាងនូវការចូលរួមនៃវិស័យឯកជន ។រីឯកាំ កងចក្រចំនួន ៩ តំណាងនូវសមាសភាពក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គមទាំង ៩ រូប

- រូបមនុស្សប្រុស-ស្រី ស្ថិតនៅខាងក្នុងកងចក្រ តំណាងនូវកម្មករនិយោជិត ដែលត្រូវទទួលបានការការពារពីរបបសន្តិសុខសង្គមតាមច្បាប់ ។

**ប្រការ ៣.-**

សញ្ញារបស់បេឡាជាតិរបបសន្តិសុខសង្គម ត្រូវបានប្រើប្រាស់ជាផ្លូវការ ដូចខាងក្រោម ៖

- ប្រើប្រាស់លើក្បាលលិខិតជាផ្លូវការរបស់អង្គភាព
- ដាក់នៅកន្លែងធ្វើការ
- ពាក់នៅលើឯកសណ្ឋានមន្ត្រីរាជការរបស់អង្គភាព
- ប្រើប្រាស់ជាផ្លូវការផ្សេងៗ

**ប្រការ ៤.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨

**រដ្ឋមន្ត្រី**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ " ដើម្បីជូនជ្រាប
- កាលប្បវត្តិ និងឯកសារ

ឧបសម្ព័ន្ធនៃប្រកាសលេខ ២៣៣ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៨
ស្តីពីការបង្កើតសញ្ញារបស់បេឡាជាតិរបបសន្តិសុខសង្គម